# អភិបាលកិច្ចក្នុងអង្គការមិនមែនរដ្ឋាភិបាល

ដោយ ឡេង ឆាយ

## និយមន័យ

អភិបាលកិច្ចគឺជាវិធីដែលអំណាចត្រូវបានប្រើប្រាស់ក្នុងអង្គការមួយ។ អភិបាលកិច្ចល្អ ធានាបាននូវគណនេយ្យភាព និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងអង្គការ និងធនធានរបស់អង្គការ [1]។

## សមាសធាតុនៃអភិបាលកិច្ចល្អ:

### ១. គណនេយ្យភាព (ការទទួលខុសត្រូវ)

គណនេយ្យភាពជាស្ថានភាពមួយ ដែលបុគ្គលិក និងអ្នកគ្រប់គ្រងមានសមត្ថភាពអាចឆ្លើយពន្យល់ ទៅលើសកម្មភាពរបស់គេ ចំពោះអ្នកពាក់ព័ន្ធនានា។

### ២. តម្លាភាព

តម្លាភាពជាស្ថានភាពមួយ ដែលអ្នកគ្រប់គ្រងអង្គការផ្តល់ព័ត៌មាន (ដូចជា អំពីប្រព័ន្ធដំណើរការ ធនធាន ថវិកា...) ដល់អ្នកពាក់ព័ន្ធនានា។

### ៣. ភាពដែលអាចព្យាករណ៍បាន

ភាពដែលអាចព្យាករណ៍បាន គឺជាបករការដែលអង្គការមាន លក្ខន្តិក: គោលនយោបាយ គោលការណ៍ និងយន្តការដទៃទៀត ដើម្បីធ្វើជាមាគ៌ា ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងការប្រតិបត្តិរបស់អង្គការ។

---

[1] ឯកសារបោះពុម្ពរបស់ VBNK: សញ្ញាណនៃក្រុមប្រឹក្សាភិបាល និងអភិបាលកិច្ច

The article is shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.

## ៤. ការចូលរួម

ការចូលរួមមានន័យថា ការបញ្ចូលបុគ្គលិក និងអ្នកពាក់ព័ន្ធ ទៅក្នុងដំណើរការនៃ ការធ្វើសេចក្តីសំរេចចិត្ត ដែលមានការប៉ះពាល់ដល់ពួកគេ។

## កំរិតនៃការចូលរួម:

រវាងអ្នកដឹកនាំ និងបុគ្គលិក ឬ រវាងអង្គការ និងក្រុមគោលដៅ

| ផ្តល់ព័ត៌មាន | ពិគ្រោះយោបល់ | ភាពជាដៃគូ | គ្រប់គ្រងដោយខ្លួនឯង |
|---|---|---|---|
| អ្នកដឹកនាំឬអង្គការ ធ្វើការសំរេចចិត្ត បន្ទាប់មកពន្យល់ និងផ្តល់ព័ត៌មាន ដល់បុគ្គលិក ឬ ក្រុមគោលដៅ។ | អ្នកដឹកនាំឬអង្គការ ធ្វើការសំរេចចិត្ត ប៉ុន្តែពិគ្រោះយោបល់ ជាមួយបុគ្គលិកឬ ក្រុមគោលដៅជាមុន មុននឹងសំរេច។ | អ្នកដឹកនាំ និង បុគ្គលិក ឬ<br><br>អង្គការ និងក្រុំគោលដៅ ធ្វើសេចក្តីសំរេច រួមគ្នា។ | អ្នកដឹកនាំ ផ្តល់អំណាច ដល់បុគ្គលិកដែលមាន សមត្ថភាពសំរេច ឬ<br><br>អង្គការអោយ ក្រុមគោលដៅ ធ្វើសេចក្តីសំរេច ដោយខ្លួនឯង។ |

អ្នកដឹកនាំ ←→ បុគ្គលិក

អង្គការ ←→ ក្រុមគោលដៅ

The article is shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.